**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
**សភាផ្នែករដ្ឋប្បវេណី**
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៨៤
ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០០០
**សាលដីកា**
លេខ:១៨៨
ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន
២-លោក **ប៉ែន ស៊ុន** ជាចៅក្រមរបាយការណ៍
៣-លោក **ប្រាក់ គឹមសាន** ជាចៅក្រម
៤-លោក **ជីវ កេង** ជាចៅក្រម
៥-លោក **សោម សិរិវឌ្ឍ** ជាចៅក្រម

**ក្រឡាបញ្ជី**

-លោកស្រី **ភួង ចន្ថា**

**តំណាងមហាអយ្យការ**

-ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំនះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៨៦៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៩ នៃសំណុំ រឿងរដ្ឋប្បវេណីលេខ ៤០៤ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អ៊ីវត្យេ អ៊ីវន ភេទស្រីអាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរបើកក្លឹនិចបូរីកីឡា ទីលំនៅផ្ទះលេខ ១៧២ ផ្លូវ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឳពុកឈ្មោះយីលាន (ស) ម្តាយឈ្មោះកាន ហន (ស) ប្តីឈ្មោះ ប៊ួន គេកឡាយ ។

បានផ្ទេរសិទ្ធិឱ្យអ្នកស្រីបិន រ៉ូហ្សែត សុគន្ធារី ។ មានមេធាវីលោក អ៊ា ដារ៉ា ។

និងចុងបណ្តឹងសាទុក្ខឈ្មោះចេវ គឹមហេង ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានមន្ទីរគណៈបក្សប្រជាជនទីលំនៅផ្ទះលេខ ១៧២$E_0E_1$ $E_2$ ផ្លូវ១៦៩សង្កាត់វាលវង់ ខណ្ឌ៧មករាក្រុងភ្នំពេញ ។

បានផ្ទេរសិទ្ធិឱ្យលោក ព្រហ្ម គន្ធ ។

**កម្មវត្ថុបណ្តឹង:** សុំរំលាយកិច្ចសន្យាជួលទីតាំងក្លឹនិចបូរីកីឡា ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៥ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០០ របស់អ្នកស្រី អ៊ីត្យេ អ៊ីវន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ ៨៦៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៨៤ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០០ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី៣០-០៩-៩៨ របស់ដើមចោទថាៈ កាលពីថ្ងៃទី១០-១១-៩៣ គណៈបក្សប្រជាជនរាជធានីភ្នំពេញ បានជួលទីតាំងផ្ទះ ១៧២$E_0E_1E_2$ ឱ្យទៅចុងចម្លើយបើកក្លឹបនិចប្ញូរីកីឡា ។ ចុងចម្លើយបានបង់ឈ្នួលផ្ទះ ខែ ១១-៩៥ មិនគ្រប់ចំនួន ហើយចាប់តាំងពីខែ ១២-៩៥ មិនគ្រប់ចំនួន ហើយចាប់តាំងពីខែ ១២-៩៥ មិនគ្រប់ចំនួន ហើយចាប់តាំងពីខែ ១២-៩៥ រហូតមកមិនបង់ឈ្នួលផ្ទះតែម្ដង ។ ក្រោយៗមក ខាងគណៈបក្សប្រជាជនបាន ធ្វើលិខិតអញ្ជើញចុងចម្លើយ ចេះតែគេចវេះពុំព្រមជួបពុំព្រមទទួលលិខិតអញ្ជើញ ហើយពុំព្រមអនុវត្តកិច្ចសន្យា។ ភាគីខ្លួនបានបន្ថយឈ្នួលមកត្រឹម ១៥០០$ ក្នុងមួយឆ្នាំតាំងពីឆ្នាំ៩៥ មក។ប្រាក់កក់ ២១៥០០$ ជានាបានតែត្រឹមខែ៦ ឆ្នាំ៩៧ ប៉ុណ្ណោះ ។ ខ្លួនសុំរំលាយកិច្ចសន្យា ចុះថ្ងៃទី ១០-១១-៩៣ និងសុំប្រាក់ឈ្នួលផ្ទះ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ១២៣(ក) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្ដីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ៣០ កញ្ញា ឆ្នាំ១៩៩៨ របស់ឈ្មោះចេវ គឹមហេង ជាដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទទួលស្គាល់ការផ្ទេរសិទ្ធិរបស់ឈ្មោះសាន់ យ៉ាន់ទ្រី ឱ្យទៅឈ្មោះ ចេវ គឹមហេង ចុះថ្ងៃទី២៥ ១២-៩៤ និងរបស់ឈ្មោះ ចេវ គឹមហេង ឱ្យទៅឈ្មោះព្រហ្ម គន្ធ ចុះថ្ងៃទី ០៦-១០-៩៨ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-រំលាយកិច្ចសន្យាចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការជួលទីតាំងផ្ទះលេខ ១៧២$E_0E_1E_2$ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ចោលជាអសារបង់ចាប់ពីថ្ងៃនេះទៅ តាមមាត្រាទី១០៧ នៃក្រឹត្យច្បាប់លេខ៣៨ ក្រច.ចុះថ្ងៃទី ២៨-១០-៨៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៤- បង្គាប់ឱ្យឈ្មោះ អ៊ីត្សេ អ៊ីវេន ហៅ យី ពៅហុង និង គ្រួសាររើសំភារៈចេញពីផ្ទះលេខ១៧២ $E_0E_1E_2$ និង$E_2$ ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ចាប់ពីសាលក្រមចូលស្ថាពរ ។

៥-ប្រគល់ផ្ទះលេខ១៧២ $E_0E_1E_2$ និង$E_2$ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញឱ្យទៅឈ្មោះ ព្រហ្ម គន្ធ តំណាងអង្គភាពគណៈបក្សប្រជាជនទីក្រុងភ្នំពេញវិញ ។

៦. បង្គាប់ឱ្យឈ្មោះ អ៊ីត្សេ អ៊ីវេន ហៅ យី ពៅហុង សងប្រាក់ថ្លៃឈ្នួលផ្ទះចំនួន១៥០០ដុល្លា (មួយពាន់ប្រាំរយ) ដុល្លាអាមេរិក ក្នុង១ខែ គិតពីខែធ្នូ ឆ្នាំ១៩៩៥ រហូតដល់ថ្ងៃអនុវត្តសាលក្រមនេះប្រាក់ឈ្នួល

ផ្ទះសំរាប់ខែ១១ឆ្នាំ១៩៩៥ ចំនួន១០០ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន ១០០០(មួយពាន់ដុល្លាអាមេរិក) ឱ្យ ទៅឈ្មោះព្រហ្ម គន្ធ តំណាងអង្គភាពគណៈបក្សប្រជាជនទីក្រុងភ្នំពេញ ។

សម្រេចរឹបអូសប្រាក់កក់ចំនួន២១.៥០០ ( ពីរម៉ឺនមួយពាន់ប្រាំរយ ) ដុល្លាអាមេរិក និងប្រាក់តម្កល់សងចំនួន៥០០(ប្រាំរយ ) ដុល្លាអាមេរិក ជានាសំណាង និង ទ្រព្យសម្បត្តិរបស់ឈ្មោះអ៊ីតៀ អ៊ីវន ហៅ យី ពៅហុង លក់ឡាយឡុងជានាសំណាង និងសម្រេចដាក់គុកបង្ខំរូបកាយឈ្មោះអ៊ីតៀ អ៊ីវន ហៅ យី ពៅហុង ចំនួន៨ខែ បើឈ្មោះនេះរឹងទទឹងមិនព្រមសងប្រាក់គ្រប់ចំនួន តាមមាត្រាទី១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រម រដ្ឋប្បវេណី ។

៧. បង្គាប់ឱ្យឈ្មោះអ៊ីតៀ អ៊ីវន ហៅ យី ពៅហុង បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣.០០០រៀល និងរង្វាន់សាក្សី ២.០០០រៀល បូករួម ៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទ បានបង់រួចជាស្រេច ។

កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ អ៊ីតៀ អ៊ីរិន ហៅ យី ពៅហុង សងប្រាក់៧០០០ រៀល ឱ្យទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួនមួយភាគរយលើប្រាក់ថ្លៃឈ្នួលផ្ទះ ដែលត្រូវបង់និងជម្ងឺចិត្ត ១.០០០ដុល្លាអាមេរិក ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០% ។

៨- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទោស់លេខ ៩៧(ក) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ របស់អ្នកស្រី អ៊ីតៀ អ៊ីវន ហៅ យី ពៅហុង ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ១២៣(ក) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ លើគ្រង់ចំណុចទាំងមូល នៃសាលក្រម ។

បានឃើញ សាលក្រមលេខ១២(ក) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី៣០-១២-៩៨ របស់ឈ្មោះ អ៊ីតៀ អ៊ីវន ហៅ យី ពៅហុង ជាដើមបណ្តឹងទាស់ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- ទទួលស្គាល់ការផ្ទេរសិទ្ធិពីឈ្មោះ អ៊ីតៀ អ៊ីវន ហៅ យី ពៅហុង ឱ្យទៅឈ្មោះ ប៊ិនរ៉ូស្សែត សុគន្ធារី ចុះថ្ងៃទី ០៤-០១-៩៩ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-តម្កល់សាលក្រមលេខ១២៣(ក)ចុះថ្ងៃទី ១៦-១២-៩៨របស់ទុកជាបានការពេញទាំងមូល ។

៤- សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខចុងបណ្តឹងទាស់ កំបាំងមុខដើមបណ្តឹងទាស់ ជាលើកទី២ ចាត់ទុកជាចំពោះមុខ សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតចាប់តាំងពីថ្ងៃ ប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៤(ក) ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ របស់ ប៊ិនរ៉ូស្សែត សុគន្ធារី ដែលប្តឹងជំទាស់នឹងសាលក្រមលេខ១២(ក) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើចំណុចទាំងមូល នៃសាលក្រម ។

បានឃើញ សាលដីកាលេខ៧៦២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩-០៤-៩៩ របស់ឈ្មោះប៊ិនរ៉ូស្សែត សុគន្ធារី ទុជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២(ក) ចុះថ្ងៃទី ១២-០២-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ១៣.០០០៛ គឺពន្ធចុះបញ្ជី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ដីកាកោះ ៥.០០០៛ អាជ្ញាធរតុលាការ ៥.០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយបើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទារសំណងលេខ ៨៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់អ្នកស្រី អ៊ីតៀ អ៊ីវន ដែលប្តឹងជំទាស់ នឹងសាលដីកាលេខ ៧៦២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើគ្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨៦៣ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសម្រេចដូចតទៅ

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១២-១១-៩៩ របស់ឈ្មោះអ៊ីតៀ អ៊ីវន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ ៧៦២ ចុះថ្ងៃទី ១៩-១០-៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយបើក ផ្លូវតវ៉ាតាមកំណាត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥៥ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០០០ របស់អ្នកស្រី អ៊ីត្យេ អ៊ីវន បានប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៨៦៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេច ទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ០៨-០៦-២០០០ របស់ឈ្មោះអ៊ីត្យេ អ៊ីវន

បានឃើញសារណាតប ចុះថ្ងៃទី ១២-០៧-២០០០ របស់ឈ្មោះព្រហ្ម គន្ធ

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ

-បណ្ដឹងសាទុក្ខរបស់ចុងចម្លើយធ្វើឡើង ក្នុងកំណត់ច្បាប់គម្បីលើកយកមកពិនិត្យពិចារណាតាមច្បាប់។

- ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ ។

ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះអ៊ីត្យេ អ៊ីវន ជាម្ចាស់បណ្ដឹងសាទុក្ខ

បានស្ដាប់ចម្លើយរបស់ឈ្មោះ ព្រហ្ម គន្ធ ជាដើមចោទ និងជាចុងបណ្ដឹងសាទុក្ខ នៅពេល ជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ក្រោយពីខ្លួនបានស្ដាប់សារណារបស់ អ្នកស្រី អ៊ីត្យេ អ៊ីវន ឃើញថារាល់ចម្លើយដែលគាត់លើកឡើងថា បានប្រគល់ប្រាក់ថ្លៃផ្ទះឱ្យមកខាងខ្លួនខ្លះហើយនៅខ្វះខ្លួននោះ គឺជាការពុំត្រឹមត្រូវឡើយ ។ ខ្លួនសូមជំរាបជូនឯកឧត្តម និងក្រុមប្រឹក្សាជំនុំជំរះឱ្យបានជ្រាបថាៈ ចាប់តាំងពីខែ១២ឆ្នាំ ១៩៩៥ អ្នកស្រីពុំដែលបានបង់ប្រាក់ថ្លៃឈ្នួលជួលផ្ទះមកខាងគណៈបក្សខ្លួនឡើយ រហូតដល់ឆ្នាំ១៩៩៦ ប្ដីរបស់គាត់ស្លាប់ទៀត ក៏គាត់មិនបានបំពេញកាតព្វកិច្ច តាមកិច្ចសន្យាឡើយ ។ ហើយព្រឹត្តិការណ៍ ថ្ងៃទី ០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ ក៏កាន់តែមិនមែនថាហេតុផលពិតប្រាកដ នៃការខកខានមិនបានបង់ប្រាក់ថ្លៃឈ្នួលផ្ទះនេះដែរ ។

ខ្លួនសូមឯកឧត្តមប្រធាន មេត្តាតម្កល់ទុកសាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែលដោយអនុគ្រោះបំផុត ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សារណារបស់អ្នកស្រី អ៊ីត្យេ អ៊ីវន និងចម្លើយដោះសារបស់លោកព្រហ្ម គន្ធ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៥ ចុះថ្ងៃទី០២.០២.២០០០ របស់អ្នកស្រី អ៊ុំតៀ អ៊ីវន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តុលាការថ្នាក់ក្រោមមុននឹងសម្រេចរឿងនេះដល់អង្គសេចក្តី បានធ្វើការស៊ើបសួរត្រឹមត្រូវ តាមនីតិវិធីហើយ ។

-យល់ឃើញថា អ្នកស្រី អ៊ុំតៀ អ៊ីវន ពុំបានបំពេញកាតព្វកិច្ចបង់ប្រាក់ថ្លៃឈ្នួលផ្ទះ តាំងពីឆ្នាំ១៩៩៥ រហូតមក ដូច្នេះដើមចោទអាចសុំរំលាយកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ១០-១១-៩៣ និងកិច្ចសន្យាចុះថ្ងៃទី ០១-០១-៩៥ បានតាមមាត្រា ១០៥ និង ១០៧ នៃក្រឹត្យច្បាប់លេខ៣៨ក្រ.ច ចុះថ្ងៃទី ២៨-១០-៨៨ ។

-យល់ឃើញថា ការដែលអ្នកស្រីអ៊ុំតៀ អ៊ីវន លើកឡើងក្នុងសារណា ចុះថ្ងៃទី០៨-០៦-២០០០ របស់អ្នកស្រីថា អ្នកស្រីសុំបន្ធូរបន្ថយថ្លៃឈ្នួលផ្ទះ និង សុំបន្តកិច្ចសន្យាជួលទៀតនោះ តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាបានទេ ពីព្រោះដើមចោទពុំបានយល់ព្រមតាមសំណូមពរនេះឡើយ ។

-យល់ឃើញថា អ្នកស្រីអ៊ុំតៀ អ៊ីវន បានធ្វើសារណាការពាររឿងក្តីរបស់អ្នកស្រីរួចហើយ ប៉ុន្តែអ្នកស្រី ពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៦២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះលោកព្រហ្ម គន្ធ កំបាំងមុខអ្នកស្រី អ៊ុំតៀ អ៊ីវន ប៉ុន្តែចាត់ទុកជាចំពោះមុខ.**

១- ទទួលបណ្តឹងសាទុក្ខលេខ ៥៥ ចុះថ្ងៃទី ០២-០២-២០០០ របស់អ្នកស្រី អ៊ុំតៀ អ៊ីវន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងធនិច្បាប់ ។

២. តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៦២ ចុះថ្ងៃទី១៩-១០-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបាន ការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោកចេវ គឹមហេង បានបង់ជួសគឺៈ

-ពន្ធចុះបញ្ជី និងពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។ ហើយតម្រូវឱ្យអ្នកស្រីអ៊ីតៀ អ៊ីវន សងប្រាក់ ១៩.០០០រៀលនេះ ទៅលោក ចេវ គឹមហេង វិញ ។

បង្គាប់ឱ្យអ្នកស្រីអ៊ីតៀ អ៊ីវន ហៅ ឃី ពៅហុង បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤. សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ។